ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

# ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តស្តង់ដារការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា



រៀបចំដោយ

គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព

ឆ្នាំ២០២៦

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ផែនទីបង្ហាញផ្លូវសម្រាប់ ការអនុវត្តស្តង់ដាការលាតត្រដាង ព័ត៌មានចីរភាពនៅកម្ពុជា

រៀបចំដោយ
គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព
ឆ្នាំ២០២៦

# អារម្ភកថា

កម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា តាមរយៈគោលនយោបាយឈ្នះ-ឈ្នះ បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ ដំណាក់កាល ដោយសម្រេចបានសមិទ្ធផលធំៗលើគ្រប់វិស័យ ទាំងនយោបាយ សង្គម សេដ្ឋកិច្ច ដែលនាំឱ្យកម្ពុជា សម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត។

សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, ឈ្លាសវៃ និងប៉ិនប្រសប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, រាជរដ្ឋាភិបាល បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ជាពិសេស បញ្ចកោណទី៤ ស្តីពីការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន ដែលជាអភិក្រម រួម និងជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មសង្គម-សេដ្ឋកិច្ច ដើម្បីធានាឱ្យសង្គមទាំងមូលអាចត្រៀមខ្លួនបានល្អ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមចម្រុះ និងភាពមិនប្រាកដប្រជានៃសកលភាវូបនីយកម្ម, ចីរភាព-បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ ស្របជាមួយគ្នានេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងផែនការ បានដាក់ឱ្យអនុវត្ត **គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០** ដែលកម្ពុជាបាន ប្តេជ្ញាចិត្តក្នុងការធ្វើឱ្យសម្រេចបានសម្រាប់ជាតិ និងរួមចំណែកសម្រាប់គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាពសកល ព្រមទាំងជំរុញសេដ្ឋកិច្ចឆ្ពោះទៅរកការសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យម កម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

ស្របតាមគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងស្ថាបត្យកម្ម ហិរញ្ញវត្ថុ, បង្កើនតម្លាភាពទីផ្សារ និងតម្រឹមការអនុវត្តថ្នាក់ជាតិ ជាមួយនឹងស្តង់ដាទទួលស្គាល់ជា អន្តរជាតិ, គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព (**គ.រ.ច.**) ត្រូវបាន បង្កើតឡើងក្នុងខែឧសភា ឆ្នាំ២០២៥។ **គ.រ.ច.** បានដើរតួនាទីជាអ្នកសម្របសម្រួល ដោយប្រមូលផ្តុំ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីធានាបាននូវកិច្ចសហប្រតិបត្តិការដែលស៊ីសង្វាក់គ្នា និង សមាមាត្រ ក្នុងការគាំទ្រដល់ការរាយការណ៍ព័ត៌មានចីរភាព។ ការកើនឡើងនូវសារៈសំខាន់នៃហានិភ័យ និងកាលានុវត្តភាពដែលទាក់ទងនឹងអាកាសធាតុ បានគូសបញ្ជាក់ពីតម្រូវការសម្រាប់ព័ត៌មានហិរញ្ញវត្ថុ ដែលទាក់ទងនឹងចីរភាព ដែលអាចប្រៀបធៀបគ្នាបាន ដើម្បីគាំទ្រដល់ស្ថិរភាពសេដ្ឋកិច្ច, ភាពធន់នៃ វិស័យហិរញ្ញវត្ថុ និងការធ្វើសេចក្តីសម្រេចចិត្ត។ ក្រុមប្រឹក្សាស្តង់ដាចីរភាពអន្តរជាតិ (ISSB) បានចេញ ផ្សាយនូវ ស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព ពោលគឺ IFRS S1 – *លក្ខខណ្ឌចាំបាច់ទូទៅសម្រាប់ ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព* និង IFRS S2 – *ការលាតត្រដាងព័ត៌មាន ទាក់ទងនឹងអាកាសធាតុ* ដោយបង្កើតមូលដ្ឋានសកលសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព។ ដើម្បី

ឆ្លើយតបនឹងការវិវត្តទាំងនេះ **គ.រ.ច.** បានបង្កើតនូវ «**ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តស្តង់ដារការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា**» ដែលកំណត់នូវក្របខណ្ឌគោលនយោបាយ, យុទ្ធសាស្ត្រ និងការបង្ហាញផ្លូវជាដំណាក់កាល សម្រាប់ការអនុវត្តស្តង់ដាអន្តរជាតិ IFRS S1 និង IFRS S2 ដោយអង្គភាពពាក់ព័ន្ធ។ ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា ត្រូវបានរៀបចំឡើងផ្អែកតាមស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព ដែលជាការអនុវត្តក្នុងលក្ខណៈបុរេសកម្ម ដើម្បីគាំទ្រដល់ប្រសិទ្ធភាពបទប្បញ្ញត្តិ និងសម្របខ្លួនជាស្រេចទៅតាមនិន្នាការតំបន់ និងសកល សំដៅធានាបាននូវឧត្តមភាពប្រកួតប្រជែង ដោយផ្អែកលើគោលការណ៍សមាមាត្រ, តាមសមត្ថភាព, អាទិភាព និងធនធានរបស់កម្ពុជា។ ផែនទីបង្ហាញផ្លូវនេះ បង្កប់នូវការអនុវត្តតាមសមាមាត្រ, ការអនុគ្រោះអន្តរកាល និងវិធានការកសាងសមត្ថភាព ដើម្បីជួយសម្រួលដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព, ពង្រឹងគុណភាព, ភាពអាចទុកចិត្តបាន និងភាពអាចប្រៀបធៀបគ្នាបាន នៃការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព។ ផែនទីបង្ហាញផ្លូវនេះ ក៏មានគោលបំណងលើកកម្ពស់គណនេយ្យភាពចំពោះផលប៉ះពាល់ផ្នែកបរិស្ថាន, សង្គម និងអភិបាលកិច្ច (ESG), កែលម្អតម្លាភាពនៃហានិភ័យ និងកាលានុវត្តភាពទាក់ទងនឹងចីរភាព ដើម្បីគាំទ្រនិងរួមចំណែកដល់វឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ និងជំរុញការវិនិយោគប្រកបដោយចីរភាព។ ផែនទីបង្ហាញផ្លូវនេះ ក៏ផ្តល់នូវឯកសារយោងគោលនយោបាយរួមសម្រាប់និយ័តករពាក់ព័ន្ធ, អង្គភាពរាយការណ៍, សវនករ និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងការអភិវឌ្ឍ, ការត្រួតពិនិត្យ និងការអនុវត្តលក្ខខណ្ឌចាំបាច់នៃការរាយការណ៍ព័ត៌មានចីរភាព។

ឆ្លៀតក្នុងឱកាសនេះ តាងនាមក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព ដែលបានរៀបចំ «**ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តស្តង់ដារការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា**» ឱ្យលេចជារូបរាងឡើង ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណជូន **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ **ន.គ.ស.** និងជាប្រធានគណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព ដែលបានដឹកនាំដោយផ្ទាល់ ព្រមទាំងក្រុមការងារបច្ចេកទេស នៃ **ន.គ.ស.** និងភាគីពាក់ព័ន្ធ ដែលបានរៀបចំ និងផ្តល់ធាតុចូលលើឯកសារផែនទីបង្ហាញផ្លូវនេះឱ្យបានគ្រប់ជ្រុងជ្រោយ និងមានភាពប្រទាក់ក្រឡាគ្នាជាមួយនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥ និងយុទ្ធសាស្ត្រពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់, ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន, អង្គភាពពាក់ព័ន្ធ និងវិស័យឯកជន នឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត «**ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តស្តង់ដារការលាត-**

**គ្រួសារព័ត៌មានចីរភាពនៅកម្ពុជា**» ឱ្យសម្រេចបានលទ្ធផលតាមការគ្រោងទុក តាមដំណាក់កាលនីមួយៗ ក្នុងបុព្វហេតុសំខាន់នៃការកសាងប្រព័ន្ធគណនេយ្យនិងសវនកម្មដែលមានភាពរឹងមាំ, តម្លាភាព និងភាពអាចទុកចិត្តបាន ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងស្ថានភាពជាក់ស្តែងរបស់កម្ពុជា។

ថ្ងៃ ចន្ទ ៦ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា គ.ស.២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


បញ្ជីពាក្យសរសេរកាត់

ខ្លឹមសារសង្ខេប ........ ១

សេចក្តីផ្តើម ........ ៣

ជំពូកទី១៖ គោលបំណង និងអត្ថប្រយោជន៍រំពឹងទុក ........ ៥

១.១. គោលបំណង ........ ៥

១.២. អត្ថប្រយោជន៍រំពឹងទុក ........ ៦

ជំពូកទី២៖ អភិក្រមនៃផែនទីបង្ហាញផ្លូវ ........ ១០

២.១. គោលការណ៍ណែនាំ ........ ១០

២.២. វិធីសាស្រ្តអនុវត្ត ........ ១២

ជំពូកទី៣៖ សហគ្រាសដែលត្រូវអនុវត្ត ........ ១៣

ជំពូកទី៤៖ លក្ខខណ្ឌចាំបាច់នៃការរាយការណ៍ និងក្របខណ្ឌពេលវេលា ........ ១៤

៤.១. លក្ខខណ្ឌចាំបាច់នៃការរាយការណ៍ ........ ១៤

៤.២. ក្របខណ្ឌពេលវេលានៃការអនុវត្ត ........ ១៩

៤.៣. ការអនុវត្តមុនកាលកំណត់ ........ ២១

៤.៤. សហគ្រាសរាយការណ៍ ........ ២១

៤.៥. ការលាតត្រដាងព័ត៌មានចីរភាពដោយសហគ្រាសធុនតូចនិងមធ្យម ........ ២១

ជំពូកទី៥៖ ទីកន្លែង និងពេលវេលានៃការលាតត្រដាង ........ ២៣

ជំពូកទី៦៖ ការអនុគ្រោះ ........ ២៤

ជំពូកទី៧៖ ការពង្រឹងអនុលោមភាព និងការតាមដាន ........ ២៦

ជំពូកទី៨៖ ការកសាងសមត្ថភាព និងការគាំទ្រ ........ ២៧

ជំពូកទី៩៖ យន្តការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវ ២៨

ជំពូកទី១០៖ វិសោធនកម្ម ........ ២៩

# បញ្ជីពាក្យសរសេរកាត់

| | |
|---|---|
| **អ.ស.ហ.** | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| **ន.គ.ស.** | និយ័តករគណនេយ្យនិងសវនកម្ម |
| **ន.ម.ក.** | និយ័តករមូលបត្រកម្ពុជា |
| **វ.ជ.ស.** | វិទ្យាស្ថានជាតិស្ថិតិ |
| **ក.អ.ក.** | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **គ.រ.ច.** | គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព |
| **វ.គ.ស.ក.** | វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា |
| CSDGs | គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា |
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច |
| EESG | សេដ្ឋកិច្ច បរិស្ថាន សង្គម និងអភិបាលកិច្ច |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| IFRS | ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ |
| IFRS S1 | ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់ការលាតត្រដាងព័ត៌មានចីរភាព លេខ ១ ស្តីពីលក្ខខណ្ឌចាំបាច់ទូទៅសម្រាប់ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព |
| IFRS S2 | ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់ការលាតត្រដាងព័ត៌មានចីរភាព លេខ ២ ស្តីពីការលាតត្រដាងព័ត៌មានទាក់ទងនឹងអាកាសធាតុ |
| ISSA | ស្តង់ដាការអះអាងចីរភាពអន្តរជាតិ |
| ISSB | ក្រុមប្រឹក្សាស្តង់ដាចីរភាពអន្តរជាតិ |

# ខ្លឹមសារសង្ខេប

ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា បានដាក់ចេញនូវទិសដៅជាយុទ្ធសាស្ត្ររបស់កម្ពុជា សម្រាប់ការអនុវត្តស្តង់ដាដែលចេញផ្សាយដោយ ក្រុមប្រឹក្សាស្តង់ដាចីរភាពអន្តរជាតិ (ISSB), ជាពិសេសស្តង់ដា IFRS S1 – លក្ខខណ្ឌចាំបាច់ទូទៅសម្រាប់ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព (General Requirements for Disclosure of Sustainability-related Financial Information) និងស្តង់ដា IFRS S2 – ការលាតត្រដាងព័ត៌មានទាក់ទងនឹងអាកាសធាតុ (Climate-related Disclosures)។ ក្រោមការរៀបចំដោយលេខាធិការដ្ឋាននៃ **គ.វ.ច**. និងអនុម័តដោយ **គ.វ.ច**, ផែនទីបង្ហាញផ្លូវនេះ មានគោលបំណងធានានូវគណនេយ្យភាពចំពោះផលប៉ះពាល់ជាសារវន្តលើបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG), ធានាតម្លាភាពលើការចូលរួមចំណែករបស់សហគ្រាសចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs), លើកកម្ពស់ភាពមើលឃើញនៃហានិភ័យនិងកាលានុវត្តភាពទាក់ទងនឹងចីរភាព, ពង្រឹងភាពធន់ និងសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុ និងជំរុញការវិនិយោគប្រកបដោយចីរភាព តាមរយៈការតម្រឹមការអនុវត្តថ្នាក់ជាតិជាមួយនឹងស្តង់ដាដែលត្រូវបានទទួលស្គាល់ជាសកល។ ការអនុវត្តនេះ ត្រូវបានរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ជាច្រើន រួមបញ្ចូលទាំងការលើកកម្ពស់ការជឿទុកចិត្តលើសាជីវកម្ម, ការកែលម្អការគ្រប់គ្រងហានិភ័យ, លទ្ធភាពក្នុងការទទួលបានដើមទុនកាន់តែប្រសើរសម្រាប់សហគ្រាសរាយការណ៍ និងការពង្រឹងស្ថិរភាព, ភាពស៊ីជម្រៅ និងភាពទាក់ទាញនៃទីផ្សារហិរញ្ញវត្ថុ និងទីផ្សារមូលធនរបស់កម្ពុជា ខណៈដែលធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានព័ត៌មានសម្រាប់និយ័តករពាក់ព័ន្ធនានា និងអ្នករៀបចំគោលនយោបាយ ដើម្បីពិនិត្យ និងតាមដានអំពីហានិភ័យជាប្រព័ន្ធ និងវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ ២០១៦-២០៣០។

ផែនទីបង្ហាញផ្លូវនេះ អនុវត្តចំពោះសហគ្រាសរាយការណ៍ចំនួន ៣ ក្រុម រួមមាន៖ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលបានចុះបញ្ជីនៅលើទីផ្សារគោល (ក្រុមទី១), ធនាគារពាណិជ្ជ, ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (ក្រុមទី២) និងសហគ្រាសដែលជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ ដែលអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ក្រុមទី៣)។ ការដាក់ឱ្យអនុវត្តនេះ ត្រូវបានចង្អុលបង្ហាញក្រោមគោលការណ៍ស្នូលសំខាន់ៗ រួមមាន៖ វិធីសាស្ត្រអនុវត្តជាជំណាក់កាល, ការផ្តោតលើភាពជាសារវន្តផ្នែកហិរញ្ញវត្ថុ (ភាពជាសារវន្តតែមួយ (Single Materiality) ស្របតាមស្តង់ដា IFRS S1 និង IFRS S2), ការលើកកម្ពស់គុណភាពនៃការលាតត្រដាងព័ត៌មានជាបន្តបន្ទាប់ និងការប្តេជ្ញាចិត្តខ្ពស់សម្រាប់ការកសាង

សមត្ថភាព និងការគាំទ្រផ្នែកបច្ចេកទេសសម្រាប់អ្នករៀបចំរបាយការណ៍, សវនករ និងនិយ័តករពាក់ព័ន្ធ។ យន្តការសមាមាត្រ និងការអនុគ្រោះអន្តរកាល ត្រូវបានដាក់បញ្ចូល ដើម្បីជៀសវាងការចំណាយច្រើនលើសលប់ រួមមាន ការរាយការណ៍ជាលើកដំបូងទាក់ទងនឹងអាកាសធាតុ, ការអនុគ្រោះលើក្របខណ្ឌពេលវេលា, ព័ត៌មានប្រៀបធៀបដែលនៅមានកម្រិត និងការអនុវត្តជាដំណាក់កាល សម្រាប់ការលាតត្រដាងព័ត៌មានអំពីការបំភាយឧស្ម័នផ្ទះកញ្ចក់ ជាពិសេសសម្រាប់ការបំភាយក្នុងវិសាលភាពទី៣ (Scope 3 GHG Emissions)។ សហគ្រាសដែលជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យវងសវនកម្មឯករាជ្យ ដែលអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម អាចជ្រើសរើសអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព។ **ន.គ.ស.** អាចនឹងរៀបចំ និងស្នើដាក់ឱ្យអនុវត្តនូវស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពសម្រាប់សហគ្រាសធុនតូចនិងមធ្យម បន្ទាប់ពីផែនទីបង្ហាញផ្លូវនេះត្រូវបានអនុម័ត។

ការដាក់ឱ្យអនុវត្ត នឹងត្រូវបែកចេញជា ៤ ដំណាក់កាលបន្តបន្ទាប់ រួមមាន៖ ដំណាក់-កាលទី១ (មូលដ្ឋានគ្រឹះ៖ ការដាក់ឱ្យអនុវត្តលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងព័ត៌មានដែលមានស្រាប់), ដំណាក់កាលទី២ (អន្តរកាល៖ ការអនុវត្តស្តង់ដា IFRS S1 និង IFRS S2 ជាមួយនឹងការអនុគ្រោះអន្តរកាល), ដំណាក់កាលទី៣ (អនុលោមភាព៖ ការដាក់ឱ្យអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2) និងដំណាក់កាលទី៤ (ការអះអាង៖ ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 ជាមួយនឹងការអះអាងពីសវនករឯករាជ្យ)។ ក្របខណ្ឌពេលវេលាសម្រាប់ការអនុវត្ត នឹងត្រូវចាប់ផ្តើមដោយសហគ្រាសនៅក្នុងក្រុមទី១ ដែលចាប់ផ្តើមសម្រាប់ដំណាក់កាលទី១ នៅឆ្នាំ២០២៦ និងបន្តចូលដំណាក់កាលទី២ នៅឆ្នាំ ២០៣០ និងឈានដល់ការតម្រូវឱ្យមានការអះអាង(ដំណាក់កាលទី៤) នៅឆ្នាំ២០៣៤ ខណៈដែលសហគ្រាសនៅក្នុងក្រុមផ្សេងទៀត អនុវត្តតាមក្របខណ្ឌពេលវេលាដែលបានកំណត់ជាបន្តបន្ទាប់។ ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព នឹងត្រូវដាក់បញ្ចូលទៅក្នុងក្របខណ្ឌបទប្បញ្ញត្តិ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ, ការជំរុញការអនុវត្ត និងការផាកពិន័យចំពោះការមិនអនុលោមតាម ព្រមទាំងមានការហាមឃាត់ដាក់លាក់ចំពោះការបំពានទៅលើយន្តការសមាមាត្រ និងការអនុគ្រោះ។ ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាពទាំងអស់ ត្រូវរៀបចំសម្រាប់អង្គភាពរាយការណ៍ ដូចគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុពាក់ព័ន្ធ ហើយត្រូវតែអាចកំណត់អត្តសញ្ញាណបានច្បាស់លាស់នៅក្នុងផ្នែក "របាយ-ការណ៍ចីរភាព" ដែលជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅរបស់សហគ្រាស។ **គ.រ.ច.** អាចធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវនេះជាបន្តបន្ទាប់ ដើម្បីឆ្លុះបញ្ចាំងពីបទពិសោធន៍នៃការអនុវត្ត និងការវិវត្តនៅក្នុងក្របខណ្ឌអន្តរជាតិ។

# ផែនទីបង្ហាញផ្លូវសម្រាប់
# ការអនុវត្តស្តង់ដារការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា

## សេចក្តីផ្តើម

នៅក្នុងខែមិថុនា ឆ្នាំ២០២៣, ISSB បានចេញផ្សាយនូវសំណុំស្តង់ដារការលាតត្រដាងព័ត៌មានចីរភាព ស្របតាម IFRS ជាលើកដំបូង រួមមាន៖ ស្តង់ដា IFRS S1 និង IFRS S2 សរុបបញ្ចូលគ្នាហៅថា ស្តង់ដារបស់ ISSB (ISSB Standards)។

កម្ពុជាបានប្តេជ្ញាចិត្តខ្ពស់ក្នុងការគាំទ្រដល់ការលាតត្រដាងព័ត៌មានទាក់ទងនឹងចីរភាព និងអាកាសធាតុ ប្រកបដោយសង្គតិភាព និងភាពអាចប្រៀបធៀបគ្នាបាន ស្របតាមស្តង់ដាអន្តរជាតិ។ ដើម្បីផ្តល់នូវការដឹកនាំ និងការសម្របសម្រួល, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានបោះមួយជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ តាមរយៈការបង្កើតនូវគណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព ហៅកាត់ថា **គ.រ.ច.** តាមរយៈប្រកាសលេខ ០៣៧ អ.ស.ហ. ប្រក. ចុះថ្ងៃទី៩ ខែឧសភា គ.ស.២០២៥។ **គ.រ.ច.** មានសមាជិកសរុបចំនួន ១៥ រូប ដែលជាតំណាងមកពីក្រសួង-ស្ថាប័ន និងអង្គភាពសំខាន់ៗ រួមមាន៖ និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**), ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (**ក.អ.ក.**), ក្រសួងផែនការ, ក្រសួងបរិស្ថាន, ធនាគារជាតិនៃកម្ពុជា, និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**), និយ័តករធានារ៉ាប់រងកម្ពុជា (**ន.ធ.ក.**), វិទ្យាស្ថានជាតិស្ថិតិ (**វ.ជ.ស.**) និងក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្ម ដែលជាសមាជិកសកម្មនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**)។ ការប្រមូលផ្តុំក្រសួង-ស្ថាប័ន និងអង្គភាពសំខាន់ៗទាំងនេះឱ្យនៅក្រោមវេទិកាតែមួយ បានឆ្លុះបញ្ចាំងពីការទទួលស្គាល់របស់កម្ពុជាថា ការរាយការណ៍ព័ត៌មានចីរភាព គឺជាបញ្ហាមួយដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការពីគ្រប់វិស័យពាក់ព័ន្ធ និងធានាថា ការរាយការណ៍ព័ត៌មានចីរភាពនៅកម្ពុជា ត្រូវបានរៀបចំប្រកបដោយសង្គតិភាព ក្រោមកិច្ចសហប្រតិបត្តិការថ្នាក់ជាតិរួមគ្នាតែមួយ។

ជាមួយការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់គុណភាព និងសង្គតិភាពនៃព័ត៌មានហិរញ្ញវត្ថុ ដែលត្រូវបានលាតត្រដាងសម្រាប់វិនិយោគិន, ស្ថាប័នផ្តល់ប្រាក់កម្ចី, អ្នកផ្តល់ប្រាក់កម្ចី និងម្ចាស់បំណុល, និយ័តករពាក់ព័ន្ធ, និងភាគីពាក់ព័ន្ធផ្សេងទៀត, **គ.រ.ច.** ផ្តល់នូវព័ត៌មានលម្អិតអំពីការអនុវត្តស្តង់ដារការលាតត្រដាងព័ត៌មានចីរភាព ដែលបច្ចុប្បន្ន រួមមាន ស្តង់ដា IFRS S1 និង IFRS S2។

ស្របតាមចលនាជាសកលឆ្ពោះទៅកាន់ការរាយការណ៍ព័ត៌មានចីរភាព ប្រកបដោយតម្លាភាព, សង្គតិភាព និងភាពអាចប្រៀបធៀបគ្នាបាន, និយ័តករពាក់ព័ន្ធ, ក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ នឹងដាក់ចេញនូវបទប្បញ្ញត្តិនានា ស្របតាមផែនទីបង្ហាញផ្លូវនេះ សម្រាប់សហគ្រាសដែលស្ថិតក្រោមដែនសមត្ថកិច្ចត្រួតពិនិត្យរបស់ខ្លួន ក្នុងការអនុវត្តស្តង់ដាការលាត-ត្រដាងព័ត៌មានចីរភាព។

## ជំពូកទី១៖ គោលបំណង និងអត្ថប្រយោជន៍រំពឹងទុក

### ១.១. គោលបំណង

គោលបំណងនៃផែនទីបង្ហាញផ្លូវនេះ គឺដើម្បីធានាថា ការលាតត្រដាងព័ត៌មានចីរភាព គឺជាឧបករណ៍មួយសម្រាប់គណនេយ្យភាព, តម្លាភាព និងភាពធន់សម្រាប់វិស័យហិរញ្ញវត្ថុ។ ផែនទីបង្ហាញផ្លូវនេះ មានគោលបំណងជាក់លាក់ ដូចខាងក្រោម៖

ក) **ធានាគណនេយ្យភាពចំពោះផលប៉ះពាល់៖** តម្រូវឱ្យសហគ្រាសរាយការណ៍ធ្វើការលាតត្រដាងព័ត៌មានអំពីផលប៉ះពាល់ជាសារវន្តផ្នែកបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដើម្បីបង្ហាញពីគណនេយ្យភាពចំពោះផលប៉ះពាល់ដែលកើតចេញពីសកម្មភាពប្រតិបត្តិការរបស់ខ្លួនទៅលើសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ខ) **ធានាគណនេយ្យភាពចំពោះវឌ្ឍនភាព៖** ធានាតម្លាភាពលើការចូលរួមចំណែកដែលអាចវាស់វែងបានរបស់សហគ្រាស ចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs) ដែលដើរតួនាទីជាកត្តាជំរុញ ដើម្បីផ្តល់អាទិភាពដល់ការចូលរួមចំណែកនោះ និងធានាឱ្យបាននូវទិសដៅស្របគ្នារវាងការប្រតិបត្តិរបស់សហគ្រាស និងការអភិវឌ្ឍប្រកបដោយចីរភាពថ្នាក់ជាតិជាអាទិភាព។

គ) **លើកកម្ពស់តម្លាភាពអំពីហានិភ័យ និងកាលានុវត្តភាព៖** តម្រូវឱ្យមានការលាត-ត្រដាងព័ត៌មានដែលអនុញ្ញាតឱ្យវិនិយោគិន, អ្នកផ្តល់ប្រាក់កម្ចី, និងនិយ័តករពាក់ព័ន្ធអាចវាយតម្លៃបានអំពីហានិភ័យ, កាលានុវត្តភាព និងភាពធន់ ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តដែលមានព័ត៌មានគ្រប់គ្រាន់ និងការបែងចែកមូលធនប្រកបដោយការទទួលខុសត្រូវ។

ឃ) **ពង្រឹងភាពធន់នៃវិស័យហិរញ្ញវត្ថុ៖** គាំទ្រដល់ស្ថិរភាពនិងសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ដោយអនុញ្ញាតឱ្យស្ថាប័នហិរញ្ញវត្ថុអាចវាយតម្លៃបានអំពីភាពខ្លាំង និងភាពងាយរងគ្រោះ ពាក់ព័ន្ធនឹងចីរភាពរបស់អ្នកខ្ចីប្រាក់ ដែលជាផ្នែកមួយនៃការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យ។

ង) **ជំរុញការវិនិយោគប្រកបដោយចីរភាពនៅកម្ពុជា៖** ប្រែក្លាយកម្ពុជាជាគោលដៅវិនិយោគមួយ ប្រកបដោយភាពទាក់ទាញ និងទំនុកចិត្តពីបណ្តាវិនិយោគិនដែលយកចិត្តទុកដាក់ខ្ពស់ចំពោះព័ត៌មានចីរភាព តាមរយៈការអនុវត្តការលាតត្រដាងព័ត៌មានថ្នាក់ជាតិ ស្របតាមស្តង់ដាការរាយការណ៍ព័ត៌មានចីរភាព ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

ការពិពណ៌នាអំពីគោលបំណងដ៏ទូលំទូលាយនេះ ចង្អុលបង្ហាញអំពីការដាក់ឱ្យអនុវត្តជាដំណាក់កាល និងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ី ដែលបានកំណត់នៅក្នុងផ្នែកបន្តបន្ទាប់នៃផែនទីបង្ហាញផ្លូវនេះ។

## ១.២. អត្ថប្រយោជន៍រំពឹងទុក

ការអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅការដាក់បញ្ចូលការពិចារណាអំពីចីរភាពទៅក្នុងប្រព័ន្ធនៃការរាយការណ៍ហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្ពុជា។ ការអនុវត្តនេះ នឹងជួយពង្រឹងដល់ស្ថាបត្យកម្មហិរញ្ញវត្ថុរបស់កម្ពុជា, បង្កើនទំនុកចិត្តក្នុងទីផ្សារ និងប្រែក្លាយកម្ពុជាទៅជាអ្នកចូលរួមដ៏គួរឱ្យទុកចិត្តមួយក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាពជាសកល។ ដោយទទួលបានអនុសាសន៍ពីនិយ័តករគណនេយ្យ និងសវនកម្ម **គ.វ.ច.** នឹងបន្តធ្វើការវាយតម្លៃ និងអនុម័តស្តង់ដារបស់ ISSB ស្របតាមការវិវត្តនៃស្តង់ដានេះ ដើម្បីធានាបាននូវការអនុវត្ត និងភាពអាចប្រៀបធៀបគ្នាបានថ្នាក់ជាតិប្រកបដោយសង្គតិភាព។

អត្ថប្រយោជន៍រំពឹងទុក នៃការអនុវត្តស្តង់ដានេះ ត្រូវបានសង្ខេបដូចខាងក្រោម៖

### សម្រាប់សហគ្រាសរាយការណ៍

ការអនុវត្តស្តង់ដានេះ ជួយពង្រឹងគណនេយ្យភាពសាជីវកម្ម, ប្រសិទ្ធភាពប្រតិបត្តិការ និងសមត្ថភាពប្រកួតប្រជែងរយៈពេលវែង តាមរយៈការដាក់បញ្ចូលព័ត៌មានចីរភាពទៅក្នុងសកម្មភាពអាជីវកម្មស្នូលរបស់សហគ្រាស។

ក) **ការបង្កើនភាពគួរឱ្យទុកចិត្ត៖** ការអនុវត្តស្តង់ដាការរាយការណ៍ព័ត៌មានចីរភាពដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ អាចបង្កើនភាពគួរឱ្យទុកចិត្តនៃការលាត-ត្រដាងព័ត៌មានរបស់សហគ្រាស និងកសាងការជឿទុកចិត្ត ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់ភាគីពាក់ព័ន្ធ។

ខ) **ការគ្រប់គ្រងហានិភ័យ និងភាពធន់ជាយុទ្ធសាស្ត្រ៖** លើកកម្ពស់ការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងហានិភ័យនិងកាលានុវត្តភាពទាក់ទងនឹងចីរភាពទៅតាមរចនាសម្ព័ន្ធច្បាស់លាស់ ដើម្បីពង្រឹងការបន្តសកម្មភាពអាជីវកម្ម និងសមត្ថភាពសម្របខ្លួនរបស់សហគ្រាស។

គ) **ការទទួលបានដើមទុន និងប្រសិទ្ធផលថ្លៃដើម៖** ជួយធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រាសក្នុងការទទួលបានដើមទុន ប្រកបដោយការទទួលខុសត្រូវ និងអាចកាត់បន្ថយថ្លៃដើមក្នុងការទទួលបានហិរញ្ញប្បទាន តាមរយៈការលាតត្រដាងព័ត៌មានចីរភាពដែលគួរឱ្យទុកចិត្តបាន និងមានគុណភាពខ្ពស់។

ឃ) **ឧត្តមភាពប្រតិបត្តិការ និងការវិភាគគោល៖** លើកទឹកចិត្តការកែលម្អដំណើរការអាជីវកម្ម, នវានុវត្តន៍ និងការប្រៀបធៀបសមត្ថភាពជាមួយសហគ្រាសក្នុងវិស័យដូចគ្នា ដើម្បីជំរុញការបង្កើនសមត្ថភាពអនុវត្តការងារជាបន្តបន្ទាប់ ជាមួយនឹងវិស័យពាក់ព័ន្ធនានា។

## សម្រាប់ទីផ្សារហិរញ្ញវត្ថុ និងទីផ្សារមូលធន

ការអនុវត្តស្តង់ដានេះ នឹងជួយបង្កើនតម្លាភាព និងគណនេយ្យភាពក្នុងប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុរបស់កម្ពុជាទាំងមូល ដោយផ្តល់នូវសិទ្ធិអំណាចដល់វិនិយោគិន និងអ្នកផ្តល់ប្រាក់-កម្ចី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ជាមួយនឹងព័ត៌មានគ្រប់ជ្រុងជ្រោយ ប្រកបដោយការទទួលខុសត្រូវ និងការយល់ដឹងអំពីហានិភ័យ។

ក) **ការធ្វើសេចក្តីសម្រេចចិត្តក្នុងការវិនិយោគ និងការផ្តល់ប្រាក់កម្ចី ជាមួយនឹងព័ត៌មានគ្រប់ជ្រុងជ្រោយ៖** ផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបាន និងអាចប្រៀប-ធៀបគ្នាបាន អំពីហានិភ័យនិងកាលានុវត្តភាពទាក់ទងនឹងចីរភាព ដែលអនុញ្ញាតឱ្យវិនិយោគិន និងស្ថាប័នហិរញ្ញវត្ថុ អាចវាយតម្លៃអំពីទស្សនវិស័យរយៈពេលវែង និងភាពធន់របស់សហគ្រាសរាយការណ៍។

ខ) **ស្ថិរភាពទីផ្សារ និងវិស័យធនាគារ៖** កាត់បន្ថយភាពមិនស៊ីសង្វាក់គ្នានៃព័ត៌មាន, ធ្វើឱ្យប្រសើរឡើងនូវភាពមើលឃើញនៃការត្រួតពិនិត្យ និងពង្រឹងទំនុកចិត្តទាំងក្នុងទីផ្សារមូលធន និងទីផ្សារធនាគារ ដែលនឹងចូលរួមចំណែកដល់ស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ និងការរីកលូតលាស់នៃឥណទានប្រកបដោយចីរភាព។

គ) **ការផ្តល់ហិរញ្ញប្បទានផ្សារភ្ជាប់នឹងចីរភាព និងគុណភាពឥណទាន៖** អនុញ្ញាតឱ្យធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ អាចវាយតម្លៃអំពីលទ្ធផលចីរភាព និងភាពងាយ-រងគ្រោះដោយសារអាកាសធាតុរបស់អ្នកខ្ចីប្រាក់ ដើម្បីជួយគាំទ្រដល់ការពង្រីកផលិតផលហិរញ្ញវត្ថុបៃតង, អន្តរកាល និងផ្សារភ្ជាប់ជាមួយនឹងចីរភាព។

ឃ) **ផលប័ត្រ និងការគ្រប់គ្រងហានិភ័យ៖** ជួយសម្រួលដល់ការពិចារណាអំពីសមាហរណកម្មនៃព័ត៌មានចីរភាពទៅក្នុងការកសាងផលប័ត្រ, ការវាយតម្លៃហានិភ័យឥណទាន និងក្របខណ្ឌភាពគ្រប់គ្រាន់នៃដើមទុន ដើម្បីឱ្យការអនុវត្តក្នុងវិស័យហិរញ្ញវត្ថុ ស្របទៅតាមគោលបំណងសេដ្ឋកិច្ច បរិស្ថាន សង្គម និងអភិបាលកិច្ច (EESG)។

## សម្រាប់អាជ្ញាធរ និងអ្នករៀបចំគោលនយោបាយ

ស្តង់ដារនេះ នឹងជួយពង្រឹងគណនេយ្យភាព, ពង្រឹងយន្តការត្រួតពិនិត្យ និងលើកកម្ពស់ប្រព័ន្ធសេដ្ឋកិច្ចមួយប្រកបដោយតម្លាភាព និងបរិយាបន្ន។

ក) **ការត្រួតពិនិត្យទីផ្សារ និងការពង្រឹងការអនុវត្ត៖** ផ្តល់ទិន្នន័យដែលមានគុណភាពខ្ពស់ និងមានសង្គតិភាព ជូនដល់និយ័តករពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យការអនុវត្តចីរភាព និងពង្រឹងអនុលោមភាពនៃការលាតត្រដាងព័ត៌មានចីរភាព។

ខ) **តម្លាភាព និងគណនេយ្យភាព៖** បង្កើនភាពអាចមើលឃើញនៃផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមរបស់សហគ្រាស ដើម្បីកសាងការជឿទុកចិត្តជាសាធារណៈ និងការទទួលខុសត្រូវសាជីវកម្ម។

គ) **ការតាមដានអំពីវឌ្ឍនភាពនៃការអនុវត្តក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs)៖** គាំទ្រដល់ការវាស់វែងប្រកបដោយតម្លាភាពនៃការរួមចំណែករបស់វិស័យឯកជន ចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។

ឃ) **ការអនុលោមតាមបទដ្ឋានអន្តរជាតិ៖** ការអនុវត្តស្តង់ដារ ISSB នឹងធ្វើឱ្យស្តង់ដារការរាយការណ៍ក្នុងស្រុក ស្របតាមការអនុវត្តជាអន្តរជាតិ, សម្របសម្រួលដល់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ឆ្លងដែន និងកាត់បន្ថយបន្ទុកចំពោះសហគ្រាសពហុជាតិក្នុងការអនុវត្តការលាតត្រដាងព័ត៌មានចីរភាព។

## សម្រាប់តម្រូវការជាប្រព័ន្ធ និងថ្នាក់ជាតិ

ស្តង់ដារនេះ ជំរុញអាទិភាពជាយុទ្ធសាស្ត្ររបស់កម្ពុជា ដោយដាក់បញ្ចូលការពិចារណាអំពីចីរភាពទៅក្នុងក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុថ្នាក់ជាតិ និងការរៀបចំគោលនយោបាយ។

ក) **ការសម្របខ្លួន និងការប្រកួតប្រជែងជាសកល៖** ធ្វើឱ្យការអនុវត្តការរាយការណ៍ថ្នាក់ជាតិ ស្របតាមស្តង់ដារអន្តរជាតិ, កាត់បន្ថយការត្រួតគ្នានៃការអនុលោមតាមច្បាប់ និងបង្កើនភាពជឿទុកចិត្ត និងភាពទាក់ទាញ ក្នុងនាមជាគោលដៅមួយសម្រាប់វិនិយោគិនដែលយកចិត្តទុកដាក់អំពីចីរភាព។

ខ) **សុខដុមនីយកម្ម និងប្រសិទ្ធភាព៖** បង្កើតមូលដ្ឋាននៃការរាយការណ៍ដែលស៊ីសង្វាក់គ្នារវាងនិយ័តករពាក់ព័ន្ធ និងវិស័យនានា ដែលនឹងកាត់បន្ថយភាពស្មុគស្មាញ, ធានាសង្គតិភាពទិន្នន័យ និងលើកកម្ពស់អន្តរប្រតិបត្តិការរវាងប្រព័ន្ធរាយការណ៍ហិរញ្ញវត្ថុផ្សេងៗ។

គ) **ការអភិវឌ្ឍ និងការធ្វើសមាហរណកម្មគោលនយោបាយ៖** ផ្តល់ទិន្នន័យអំពីចីរភាពដែលមានស្តង់ដាររួម ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយ ដោយផ្អែកលើភស្តុតាងពាក់ព័ន្ធនឹងហិរញ្ញវត្ថុប្រកបដោយចីរភាព, សកម្មភាពទាក់ទងនឹងអាកាសធាតុ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព។

ឃ) **កាតាលីករសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន៖** ដាក់បញ្ចូលការពិចារណាអំពីចីរភាពទៅក្នុងការរាយការណ៍និងការធ្វើសេចក្តីសម្រេចចិត្តរបស់អាជីវកម្មដែលអនុញ្ញាតឱ្យសហគ្រាសអាចគ្រប់គ្រងហានិភ័យ, ធ្វើនវានុវត្តន៍ និងស្វែងរកកាលានុវត្តភាពថ្មីៗដែលបង្កើតបានតម្លៃរួមដល់បរិស្ថាន និងសង្គម។

## ជំពូកទី២៖ អនិក្រមនៃផែនទីបង្ហាញផ្លូវ

### ២.១. គោលការណ៍ណែនាំ

ការដាក់ឱ្យអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា ស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ត្រូវបានចង្អុលបង្ហាញដោយគោលការណ៍ស្នូលចំនួន ៥ ដែលធានាថា ផែនទីបង្ហាញផ្លូវនេះ អាចជឿទុកចិត្តបាន, មានសមាមាត្រសមស្របតាមបរិបទ និងអាចអនុវត្តបានក្នុងបរិបទនៃបទប្បញ្ញត្តិនិងទីផ្សារនៅកម្ពុជា។

១) **ការអនុវត្តជាដំណាក់កាល៖** ការឆ្ពោះទៅអនុវត្តស្តង់ដារបស់ ISSB គឺជាដំណើរដែលមានរចនាសម្ព័ន្ធច្បាស់លាស់មួយ ដែលទាមទារពេលវេលា, ការសម្របខ្លួន និងកិច្ចសហការ។ លក្ខខណ្ឌចាំបាច់នៃការរាយការណ៍ នឹងត្រូវបានកំណត់តាមដំណាក់កាលជាបន្តបន្ទាប់ ដែលអនុញ្ញាតឱ្យសហគ្រាសអាចធ្វើសមាហរណកម្មការពិចារណាអំពីចីរភាព ទៅក្នុងប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពក្នុងការលាតត្រដាងព័ត៌មានជាបន្តបន្ទាប់។

២) **ការផ្តោតលើភាពជាសារវន្តហិរញ្ញវត្ថុ៖** ការអនុវត្តវិធីសាស្ត្រភាពជាសារវន្តតែមួយ (Single Materiality) ដើម្បីធានានូវសង្គតិភាពជាមួយស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព IFRS S1 និង IFRS S2 ដែលតម្រូវឱ្យមានការលាតត្រដាងបញ្ហាអំពីចីរភាពដែលអាចត្រូវបានរំពឹងទុកដោយមានហេតុផលសមស្របថានឹងមានឥទ្ធិពលលើទស្សនវិស័យរបស់សហគ្រាស។ ការផ្តោតនេះធានាថា ព័ត៌មានដែលបានរាយការណ៍នៅតែរក្សាបានសារៈសំខាន់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តរបស់វិនិយោគិន និងអ្នកផ្តល់មូលធនហិរញ្ញវត្ថុផ្សេងទៀត ខណៈដែលបន្តរក្សាបាននូវសង្គតិភាពជាមួយនឹងស្តង់ដាអន្តរជាតិ។

៣) **ការលាតត្រដាងព័ត៌មានជាបន្តបន្ទាប់៖** ភាពស៊ីជម្រៅ និងវិសាលភាពនៃការលាតត្រដាងព័ត៌មានដែលបានតម្រូវ នឹងមានការកើនឡើងជាបន្តបន្ទាប់ នៅពេលប្រព័ន្ធ, ទិន្នន័យ និងសមត្ថភាពនៃការអះអាងរបស់អ្នករៀបចំរបាយការណ៍ មានការរីកចម្រើន។ វិធីសាស្ត្រនេះ គាំទ្រដល់ការកែលម្អជាបន្តបន្ទាប់ ដោយមិនបង្កើតជាបន្ទុកអនុលោមភាព ដែលលើសពីសមត្ថភាពរបស់សហគ្រាស ហើយមានសង្គតិភាពជាមួយនឹងយន្តការសមាមាត្ររបស់ ISSB។

៤) **ការកសាងសមត្ថភាព និងការគាំទ្រ៖ គ.រ.ច.** មានភារកិច្ចធានាថា ការគាំទ្រលើការងារកសាងសមត្ថភាពដ៏រឹងមាំ គឺជាចំណុចដ៏សំខាន់មួយសម្រាប់ការផ្តល់សិទ្ធិ

អំណាចដល់សហគ្រាសរាយការណ៍។ **គ.រ.ប.** ក្រោមកិច្ចសហការជាមួយនឹងស្ថាប័នវិជ្ជាជីវៈផ្សេងទៀត នឹងផ្តល់ជំនួយបច្ចេកទេស, ការបណ្តុះបណ្តាល និងសេចក្តីណែនាំជាបន្តបន្ទាប់ ដល់អ្នករៀបចំរបាយការណ៍, សវនករ និងនិយ័តករពាក់ព័ន្ធ ដើម្បីធានាបាននូវការត្រៀមលក្ខណៈរួចរាល់សម្រាប់គ្រប់ដំណាក់កាលនៃការអនុវត្ត។

៥) **ភាពបត់បែននៃបទប្បញ្ញត្តិ និងយន្តការសមាមាត្រ៖** កាតព្វកិច្ចរាយការណ៍នឹងនៅតែមានភាពសមាមាត្រទៅនឹងទំហំសហគ្រាស, វិស័យ និងសារៈសំខាន់ជាប្រព័ន្ធ។ ភាពបត់បែនក្នុងការរៀបចំ និងពេលវេលា នឹងប្រើប្រាស់យន្តការសមាមាត្ររបស់ ISSB ដូចជា ការលើកលែងចំពោះ "ការចំណាយ ឬ ការខិតខំប្រឹងប្រែងច្រើនលើសលប់" និងការពឹងផ្អែកលើជំនាញ និងធនធានដែលមានស្រាប់ ដើម្បីធានាថា ការរាយការណ៍ព័ត៌មានចីរភាពនៅតែអាចអនុវត្តបាន និងមានភាពពាក់ព័ន្ធ។

## ២.២. វិធីសាស្ត្រអនុវត្ត

ដោយទទួលស្គាល់ពីអត្ថប្រយោជន៍នៃការអនុវត្តស្តង់ដារការលាតត្រដាងព័ត៌មានចីរភាពស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ, ការដាក់ឱ្យអនុវត្តលក្ខខណ្ឌ-ចាំបាច់នៅកម្ពុជា មិនអាចធ្វើទៅបាន ដោយពុំមានការអភិវឌ្ឍ និងការកសាងសមត្ថភាពជាមុននោះទេ។ ដូចនេះ ផែនទីបង្ហាញផ្លូវនេះ មានគោលបំណងកំណត់អំពីការអនុវត្តជាជំហានៗ ដោយពិចារណាអំពីបន្ទុកអនុលោមភាព និងផ្តល់ពេលវេលាសមស្រប សម្រាប់ការកសាងសមត្ថភាព។ ផ្អែកលើគោលការណ៍ដែលបានកំណត់ខាងលើ, ផែនទីបង្ហាញផ្លូវនេះ ប្រើប្រាស់វិមាត្រចំនួន ៣ សម្រាប់ការអនុវត្ត ដូចបានបង្ហាញក្នុងដ្យាក្រាមខាងក្រោម៖



## ជំពូកទី៣៖ សហគ្រាសដែលត្រូវអនុវត្ត

ផែនទីបង្ហាញផ្លូវនេះ គ្របដណ្តប់លើសហគ្រាសរាយការណ៍ ដែលរួមបញ្ចូលគ្រប់សហគ្រាសដែលមានការទទួលខុសត្រូវជាសាធារណៈទាំងអស់ ក៏ដូចជាសហគ្រាសដែលជាប់កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយរងសវនកម្មឯករាជ្យ។ សហគ្រាសរាយ-ការណ៍ដែលត្រូវអនុវត្ត មាន ៣ ក្រុម ដូចខាងក្រោម៖

| ក្រុម | សហគ្រាសរាយការណ៍ដែលត្រូវអនុវត្ត |
|---|---|
| ១ | ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលបានចុះបញ្ជីនៅលើទីផ្សារគោល |
| ២ | ធនាគារពាណិជ្ជ, ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ |
| ៣ | សហគ្រាសដែលជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ ដែលអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា |

សហគ្រាសរាយការណ៍ ត្រូវបានលើកលែងពីលក្ខខណ្ឌចាំបាច់ ប្រសិនបើសហគ្រាសរាយការណ៍មិនមែនជាក្រុមហ៊ុនចុះបញ្ជី ហើយបំពេញគ្រប់លក្ខខណ្ឌទាំង៤ ដូចខាងក្រោម៖

- ក្រុមហ៊ុនមេផ្ទាល់, ក្រុមហ៊ុនមេអន្តរការី ឬ ក្រុមហ៊ុនមេចុងក្រោយ គឺជាសហគ្រាសរបស់កម្ពុជា និង
- ក្រុមហ៊ុនមេនោះ រៀបចំរបាយការណ៍ចីរភាព ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃផែនទីបង្ហាញផ្លូវនេះ និង
- របាយការណ៍ចីរភាពនោះ រួមបញ្ចូលសកម្មភាពរបស់សហគ្រាសរាយការណ៍ និង
- របាយការណ៍ចីរភាពនោះ អាចស្វែងរកបានជាសាធារណៈក្នុងក្របខណ្ឌពេលវេលា និងលក្ខខណ្ឌដូចគ្នានឹងរបាយការណ៍របស់សហគ្រាសរាយការណ៍។

### ពហុលក្ខណៈវិនិច្ឆ័យ

លក្ខខណ្ឌចាំបាច់ដាច់ដោយឡែក នឹងត្រូវបានកំណត់ដោយនិយ័តករពាក់ព័ន្ធ សម្រាប់សហគ្រាសដែលបំពេញតាមពហុលក្ខណៈវិនិច្ឆ័យ។ ឧទាហរណ៍ ធនាគារពាណិជ្ជមួយដែលបានចុះបញ្ជីនៅលើទីផ្សារគោល។

## ជំពូកទី៤៖ លក្ខខណ្ឌចាំបាច់នៃការរាយការណ៍ និងក្របខណ្ឌពេលវេលា

### ៤.១. លក្ខខណ្ឌចាំបាច់នៃការរាយការណ៍

ការដាក់ឱ្យអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ជា ៤ ដំណាក់កាល ដែលដំណាក់កាលនីមួយៗនឹងពង្រីកវិសាលភាព, ភាពស៊ីជម្រៅ និងលក្ខខណ្ឌ-ចាំបាច់នៃការអះអាង ដើម្បីធានាភាពសមាមាត្រ និងការត្រៀមលក្ខណៈរួចរាល់ក្នុងគ្រប់វិស័យ។

| ១ | ២ | ៣ | ៤ |
|---|---|---|---|
| **ដំណាក់កាល មូលដ្ឋាន** | **ដំណាក់កាល អន្តរកាល** | **ដំណាក់កាល អនុលោមភាព** | **ដំណាក់កាល អះអាង** |
| ការដាក់ឱ្យអនុវត្តលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដែលមានស្រាប់ | ការដាក់ឱ្យអនុវត្តស្តង់ដា IFRS S1 និង IFRS S2 ដោយមានការអនុគ្រោះអន្តរកាល | ការដាក់ឱ្យអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 | ការដាក់ឱ្យអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 ដោយមានការអះអាងពីខាងក្រៅ |
| ស្ម័គ្រចិត្ត | អនុលោម ឬ ពន្យល់ | អនុលោមភាពចាំបាច់ | ការពង្រឹងការអនុវត្តដោយមានការអះអាង |

## ដំណាក់កាលទី១ (ដំណាក់កាលមូលដ្ឋាន)៖

### ការដាក់ឱ្យអនុវត្តលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដែលមានស្រាប់

ដំណាក់កាលទី១ ត្រូវបានរៀបចំក្នុងគោលបំណងកសាងសមត្ថភាព ដើម្បីកំណត់អំពីមូលដ្ឋានគ្រឹះសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព ដោយអនុវត្តលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដែលមានស្រាប់។ ដើម្បីធានាបាននូវភាពសមាមាត្រ, ដំណាក់កាលនេះនឹងត្រូវអនុវត្តសម្រាប់តែក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលបានចុះបញ្ជីនៅលើទីផ្សារគោល (ក្រុមទី១) និងធនាគារពាណិជ្ជ, ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួល-ប្រាក់បញ្ញើ(ក្រុមទី២) ប៉ុណ្ណោះ។

### ក្រុមទី១

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលបានចុះបញ្ជីនៅលើទីផ្សារគោល តម្រូវឱ្យអនុវត្តផែនទីបង្ហាញផ្លូវនេះ ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដែលមានស្រាប់ ដែលបានចេញដោយ និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**)។ លក្ខខណ្ឌចាំបាច់នៃការលាតត្រដាង ត្រូវបានកំណត់ក្នុងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស។ ប្រសិនបើសហគ្រាសមិនមានព័ត៌មានដូចបានកំណត់ក្នុងតារាងនោះទេ, សហគ្រាសត្រូវបានតម្រូវឱ្យបញ្ជាក់អំពីការពិតនេះ និងពន្យល់៖

ក). ថាតើមានព័ត៌មានជំនួសប្រហាក់ប្រហែល ហើយត្រូវលាតត្រដាងអំពីព័ត៌មានជំនួសនោះ ឬ បង្ហាញទីកន្លែងដែលព័ត៌មាននោះអាចស្វែងរកបានដែរឬទេ

ខ). ប្រសិនបើមិនមានព័ត៌មានជំនួសប្រហាក់ប្រហែល, ថាតើផលប៉ះពាល់នៃហានិភ័យដែលមានសក្តានុពល ត្រូវបានចាត់ទុកថាមានភាពជាសារវន្តដែរឬទេ។ ប្រសិនបើមានភាពជាសារវន្ត, សហគ្រាសរាយការណ៍គួរពន្យល់ថាតើខ្លួនកំពុងចាត់វិធានការណាមួយដើម្បីអាចលាតត្រដាងព័ត៌មានទាំងនោះក្នុងឆ្នាំបន្តបន្ទាប់បានដែរឬទេ។

### ក្រុមទី២

ធនាគារពាណិជ្ជ, ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ត្រូវបានតម្រូវឱ្យអនុវត្តផែនទីបង្ហាញផ្លូវនេះ ដើម្បីអនុលោមតាមលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដែលចេញដោយ ធនាគារជាតិនៃកម្ពុជា។

## ដំណាក់កាលទី២ (ដំណាក់កាលអន្តរកាល)៖

### ការដាក់ឱ្យអនុវត្តស្តង់ដា IFRS S1 និង IFRS S2 ដោយមានការអនុគ្រោះអន្តរកាល

សហគ្រាសរាយការណ៍ នឹងពង្រីក និងកែលម្អការលាតត្រដាងរបស់ខ្លួន ដើម្បីអនុលោមតាមស្តង់ដា IFRS S1 និង IFRS S2 ក្នុងអំឡុងពេលកំពុងអនុវត្តការអនុគ្រោះអន្តរកាល និងតាមសមាមាត្រ ដែលបានណែនាំដោយ ISSB។

### យន្តការសមាមាត្រក្នុងស្តង់ដា IFRS S1 និង IFRS S2

ISSB បានផ្តួចផ្តើមនៅក្នុងស្តង់ដា IFRS S1 និង IFRS S2 នូវ គោលគំនិត "**ព័ត៌មានសមហេតុផល និងអាចគាំទ្របាន ដែលអាចរកបាន នាកាលបរិច្ឆេទរាយការណ៍ ដោយមិនមានការចំណាយច្រើនលើសលប់**" ។ យន្តការសមាមាត្រនេះ៖

- បញ្ជាក់ថា ការវាយតម្លៃអំពីអ្វីដែលជាការចំណាយច្រើនលើសលប់ គឺអាស្រ័យលើកាលៈទេសៈជាក់ស្តែងរបស់សហគ្រាស និងតម្រូវឱ្យមានការពិចារណាដែលមានតុល្យភាពមួយរវាងការចំណាយ និងការខិតខំប្រឹងប្រែងសម្រាប់សហគ្រាស និងអត្ថប្រយោជន៍ដែលវិនិយោគិនទទួលបានពីព័ត៌មានទាំងនោះ
- សង្កត់ធ្ងន់ថា សហគ្រាសត្រូវបានតម្រូវឱ្យប្រើព័ត៌មានពាក់ព័ន្ធ និងសមស្រប និង
- បញ្ជាក់ថា សហគ្រាសមិនត្រូវបានតម្រូវឱ្យខិតខំហួសហេតុដើម្បីស្វែងរកព័ត៌មាន។

ISSB ក៏បានផ្តួចផ្តើមគោលគំនិត "**ជំនាញ, សមត្ថភាព និងធនធានដែលមាន សម្រាប់សហគ្រាស**" ដើម្បីដោះស្រាយបញ្ហាសមាមាត្រ។ យន្តការសមាមាត្រនេះ៖

- បញ្ជាក់ថា សហគ្រាសអាចអនុវត្តវិធីសាស្ត្រមួយដែលមានភាពសាមញ្ញជាង ចំពោះការវិភាគសេណារីយ៉ូទាក់ទងនឹងអាកាសធាតុ ដូចជា ការវិភាគសេណារីយ៉ូបែបគុណភាព ប្រសិនបើវិធីសាស្ត្របែបនេះ មានភាពសមស្របចំពោះកាលៈទេសៈរបស់សហគ្រាស ដែលការវិភាគនេះរួមបញ្ចូលនូវការពិចារណាអំពីការប្រឈមរបស់សហគ្រាសទៅនឹងហានិភ័យនិងកាលានុវត្តភាពទាក់ទងនឹងអាកាសធាតុ ព្រមទាំងជំនាញ, សមត្ថភាព និងធនធានដែលមានសម្រាប់សហគ្រាស សម្រាប់ការវិភាគសេណារីយ៉ូបែបនេះ។
- បញ្ជាក់ថា សហគ្រាសពុំចាំបាច់ផ្តល់ព័ត៌មានបែបបរិមាណ អំពីផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដែលបានព្យាករណ៍ទុកនៃហានិភ័យ ឬ កាលានុវត្តភាពទាក់ទងនឹងចីរភាពនោះទេ ប្រសិនបើសហគ្រាសពុំមានជំនាញ, សមត្ថភាព ឬ ធនធាន ដើម្បីផ្តល់នូវព័ត៌មានបែបបរិមាណទាំងនោះ
- បញ្ជាក់ថា កាលៈទេសៈរបស់សហគ្រាស ទំនងជាមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ហើយការវាយតម្លៃរបស់សហគ្រាសលើកាលៈទេសៈទាំងនោះ ក៏នឹងផ្លាស់ប្តូរតាមកាលៈទេសៈទាំងនោះផងដែរ។

## តារាងទី១៖ យន្តការសមាមាត្រ

| ល.រ. | លក្ខខណ្ឌចាំបាច់នៃការលាតត្រដាងនៃស្តង់ដា IFRS S1 និង IFRS S2 | ព័ត៌មានដែលបានប្រើគឺមានកំណត់ត្រឹមអ្វីដែលសមហេតុផល, អាចគាំទ្របាន និងមានស្រាប់ ដោយពុំមានការចំណាយច្រើនលើសលប់ | វិធីសាស្ត្របែបគុណភាព ត្រូវបានអនុញ្ញាត ប្រសិនបើសហគ្រាសខ្វះ: ជំនាញ, សមត្ថភាព ឬ ធនធាន |
|---|---|---|---|
| ១ | ការកំណត់ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដែលបានព្យាករណ៍ទុក | អនុញ្ញាត | អនុញ្ញាត |
| ២ | ការវិភាគសេណារីយ៉ូទាក់ទងនឹងអាកាសធាតុ | អនុញ្ញាត | អនុញ្ញាត |
| ៣ | ការវាស់វែងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) ក្នុងវិសាលភាពទី៣ | អនុញ្ញាត | |
| ៤ | ការកំណត់អត្តសញ្ញាណហានិភ័យនិងកាលានុវត្តភាព | អនុញ្ញាត | |
| ៥ | ការកំណត់អំពីវិសាលភាពនៃខ្សែ-សង្វាក់តម្លៃ | អនុញ្ញាត | |
| ៦ | ការគណនាខ្នាតរង្វាស់ក្នុងប្រភេទឆ្លងឧស្សាហកម្មមួយចំនួន | អនុញ្ញាត | |

## តារាងទី២៖ ការអនុគ្រោះអន្តរកាល

| ល.រ. | ការអនុគ្រោះអន្តរកាល |
|---|---|
| ១ | **ការរាយការណ៍ទាក់ទងនឹងអាកាសធាតុជាលើកដំបូង៖** សហគ្រាសដែលត្រូវអនុវត្តត្រូវបានអនុញ្ញាតឱ្យលាតត្រដាងព័ត៌មានអំពីហានិភ័យនិងកាលានុវត្តភាពទាក់ទងនឹងអាកាសធាតុតែប៉ុណ្ណោះ (អនុលោមតាមស្តង់ដា IFRS S2) ហើយបន្ទាប់មកអនុវត្តលក្ខខណ្ឌចាំបាច់នៃស្តង់ដា IFRS S1 តែក្នុងវិសាលភាពដែលលក្ខខណ្ឌ-ចាំបាច់ទាំងនោះ ជាប់ពាក់ព័ន្ធនឹងការលាតត្រដាងព័ត៌មានអំពីហានិភ័យ និងកាលានុវត្តភាពទាក់ទងនឹងអាកាសធាតុ។ |
| ២ | **ពេលវេលានៃការរាយការណ៍៖** សហគ្រាសដែលត្រូវអនុវត្ត ត្រូវបានអនុញ្ញាតឱ្យរាយការណ៍អំពីការលាតត្រដាងហិរញ្ញវត្ថុទាក់ទងនឹងចីរភាពប្រចាំឆ្នាំរបស់ខ្លួនបន្ទាប់ពីសហគ្រាសបានបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុពាក់ព័ន្ធរបស់ខ្លួនរួចស្របពេលជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុពាក់កណ្តាលឆ្នាំរបស់ខ្លួន។ |

| | |
|---|---|
| ៣ | **ការលាតត្រដាងព័ត៌មានប្រៀបធៀប៖** សហគ្រាសដែលត្រូវអនុវត្ត មិនត្រូវបានតម្រូវឱ្យលាតត្រដាងព័ត៌មានប្រៀបធៀបអំពីហានិភ័យនិងកាលានុវត្តភាពទាក់ទងនឹងចីរភាពរបស់ខ្លួននៅក្នុងការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំដំបូង បន្ទាប់ពីរយៈពេលអនុគ្រោះបានបញ្ចប់ ដាដាងហានិភ័យនិងកាលានុវត្តភាពទាក់ទងនឹងអាកាសធាតុ។ |
| ៤ | **ពិធីសារឧស្ម័នផ្ទះកញ្ចក់៖** សហគ្រាសដែលត្រូវអនុវត្ត ត្រូវបានអនុញ្ញាតក្នុងការមិនប្រើប្រាស់ពិធីសារឧស្ម័នផ្ទះកញ្ចក់ លុះត្រាតែសហគ្រាសនោះត្រូវបានតម្រូវដោយបទប្បញ្ញត្តិណាមួយឱ្យប្រើប្រាស់វិធីសាស្ត្រវាស់វែងផ្សេង។ |
| ៥ | **ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្នុងវិសាលភាពទី៣៖** សហគ្រាសដែលត្រូវអនុវត្ត ត្រូវបានអនុញ្ញាតក្នុងការមិនលាតត្រដាងអំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់វិសាលភាពទី៣ លើកលែងតែសម្រាប់ប្រភេទដែលបានតម្រូវរួចដោយនិយ័តករពាក់ព័ន្ធរបស់សហគ្រាសខ្លួន។ |

## ដំណាក់កាលទី៣ (ដំណាក់កាលអនុលោមភាព)៖

### ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2

សហគ្រាសនឹងត្រូវបានតម្រូវឱ្យអនុលោមពេញលេញតាមរាល់លក្ខខណ្ឌចាំបាច់នៃការលាតត្រដាងស្របតាមស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព។ ដំណាក់កាលនេះ សម្រេចបាននូវអនុលោមភាពពេញលេញតាមស្តង់ដារបស់ ISSB ដោយមិនរាប់បញ្ចូលនូវអត្ថប្រយោជន៍ណាមួយដែលទទួលបានពីការអនុគ្រោះអន្តរកាលដែលបានផ្តល់នៅក្នុងស្តង់ដាទាំងនោះ។

## ដំណាក់កាលទី៤ (ដំណាក់កាលអះអាង)៖

### ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 ដោយមានការអះអាងពីខាងក្រៅ

សហគ្រាសដែលត្រូវបានតម្រូវឱ្យលាតត្រដាងព័ត៌មានចីរភាព អនុលោមតាមស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព ត្រូវបានតម្រូវឱ្យដាក់ព័ត៌មានចីរភាពឱ្យរងសវនកម្មដោយអ្នកផ្តល់ការអះអាងពីខាងក្រៅ។ ការអះអាងពីខាងក្រៅ ត្រូវផ្តល់ដោយសវនករដែលត្រូវបានទទួលស្គាល់។ កិច្ចសន្យាអះអាង ត្រូវអនុវត្តដោយអនុលោមតាមស្តង់ដាការអះអាងចីរភាពអន្តរជាតិ (ISSA)។ លក្ខខណ្ឌចាំបាច់សម្រាប់ការទទួលស្គាល់ជាអ្នកផ្តល់ការអះអាង នឹងត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

## ៤.២. ក្របខណ្ឌពេលវេលានៃការអនុវត្ត

### តារាងទី៣៖ ក្របខណ្ឌពេលវេលានៃការអនុវត្ត[១]

| សហគ្រាសរាយការណ៍ដែលត្រូវអនុវត្ត | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | ២០៣១ | ២០៣២ [២] | ២០៣៣ [២] | ២០៣៤ [២] | ២០៣៥ |
|---|---|---|---|---|---|---|---|---|---|---|
| ក្រុមទី១៖ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលបានចុះបញ្ជីនៅលើទីផ្សារគោល | ដំណាក់កាលទី១៖ ការអនុវត្តស្របតាមលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដែលមានស្រាប់ | | | | ដំណាក់កាលទី២៖ ឆ្នាំដំបូងនៃការអនុវត្តស្តង់ដារបស់ក្រុមប្រឹក្សាស្តង់ដាចីរភាពអន្តរជាតិ ដោយមានការអនុគ្រោះអន្តរកាល | | ដំណាក់កាលទី៣៖ ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 | | ដំណាក់កាលទី៤៖ ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 ដោយមានការអះអាងពីខាងក្រៅ | |
| ក្រុមទី២៖ ធនាគារពាណិជ្ជ, ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | | ដំណាក់កាលទី១៖ ការអនុវត្តស្របតាមលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដែលមានស្រាប់ | | | ដំណាក់កាលទី២៖ ឆ្នាំដំបូងនៃការអនុវត្តស្តង់ដារបស់ក្រុមប្រឹក្សាស្តង់ដាចីរភាពអន្តរជាតិ ដោយមានការអនុគ្រោះអន្តរកាល | | ដំណាក់កាលទី៣៖ ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 | | ដំណាក់កាលទី៤៖ ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 ដោយមានការអះអាងពីខាងក្រៅ | |
| ក្រុមទី៣៖ សហគ្រាសដែលជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យវេងសវនកម្មឯករាជ្យដែលអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា | | | | | ដំណាក់កាលទី២៖ ឆ្នាំដំបូងនៃការអនុវត្តស្តង់ដារបស់ក្រុមប្រឹក្សាស្តង់ដាចីរភាពអន្តរជាតិ ដោយមានការអនុគ្រោះអន្តរកាល | | ដំណាក់កាលទី៣៖ ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 | | ដំណាក់កាលទី៤៖ ការអនុវត្តពេញលេញនៃស្តង់ដា IFRS S1 និង IFRS S2 ដោយមានការអះអាងពីខាងក្រៅ | |

**កំណត់សម្គាល់៖**

(១) គ្រប់ខណ្ឌពេលវេលានៃការអនុវត្ត ចូលជាធរមានសម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំដែលចាប់ផ្តើម ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០XX (ឧទាហរណ៍ ឆ្នាំ២០៣០ សំដៅដល់របាយការណ៍ប្រចាំឆ្នាំដែលគ្របដណ្តប់ចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០៣០)។

(២) សហគ្រាសបានទទួលការអនុគ្រោះអន្តរកាលបន្ថែម (additional transition reliefs) តាមរយៈការលើកលែងការលាតត្រដាងព័ត៌មានអំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិសាលភាពទី៣ សម្រាប់ការិយបរិច្ឆេទគណនេយ្យ ២០៣២ ដល់ ២០៣៤។ ដោយឡែក ការលាតត្រដាងព័ត៌មានពេញលេញនឹងត្រូវអនុវត្តចាប់ពីការិយបរិច្ឆេទគណនេយ្យ ២០៣៥ តទៅ។

## ៤.៣. ការអនុវត្តមុនកាលកំណត់

សហគ្រាសរាយការណ៍ អាចជ្រើសរើសអនុវត្តលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងដូចបានកំណត់ក្នុងផែនទីបង្ហាញផ្លូវនេះ មុនកាលកំណត់បាន។ សហគ្រាសរាយការណ៍អាចជ្រើស-រើសរំលងជំហានណាមួយ ឧទាហរណ៍ ដោយធ្វើការរាយការណ៍តាមលក្ខខណ្ឌចាំបាច់របស់ ISSB ភ្លាមៗតែម្តង ជំនួសឱ្យការរាយការណ៍ទៅតាមជំហានអន្តរកាល ក្រោមលក្ខខណ្ឌចាំបាច់ផ្សេងទៀត សម្រាប់ការរាយការណ៍លើកដំបូងរបស់ខ្លួន។

## ៤.៤. សហគ្រាសរាយការណ៍

ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព និងការរាយការណ៍ហិរញ្ញវត្ថុពាក់ព័ន្ធ ត្រូវរៀបចំសម្រាប់សហគ្រាសរាយការណ៍តែមួយដូចគ្នា។ ប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំជារបាយការណ៍ហិរញ្ញវត្ថុរួម (Consolidated Financial Statements), ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាពដែលភ្ជាប់មកជាមួយនោះ ក៏ត្រូវតែជាការលាតត្រដាងរួម ដូចគ្នាផងដែរ (Consolidated Sustainability-related Financial Disclosure)។

## ៤.៥. ការលាតត្រដាងព័ត៌មានចីរភាពដោយសហគ្រាសធុនតូចនិងមធ្យម

ការលាតត្រដាងព័ត៌មានចីរភាពដែលត្រូវបានរាយការណ៍ដោយសហគ្រាសធុនតូចនិងមធ្យម បង្កើតបាននូវសមាសភាពដ៏សំខាន់មួយនៃប្រព័ន្ធអេកូឡូស៊ីនៃការរាយការណ៍ព័ត៌មានចីរភាពរបស់ជាតិ។ ជាមួយគ្នានេះ ការអភិវឌ្ឍ និងការពង្រឹងការអនុវត្តការរាយការណ៍ព័ត៌មានចីរភាពរបស់សហគ្រាសធុនតូចនិងមធ្យម នឹងត្រូវបានទទួលស្គាល់ជាអាទិភាពមួយ ដើម្បីគាំទ្រដល់ការដាក់ឱ្យអនុវត្តផែនទីបង្ហាញផ្លូវនេះ។

នៅកម្ពុជា, សហគ្រាសធុនតូចនិងមធ្យម គឺជាផ្នែកមួយដ៏សំខាន់ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់នៃក្រុមហ៊ុនដែលបានចុះបញ្ជីនៅលើទីផ្សារគោល និងក្រុមហ៊ុនធំៗដែលមិនចុះបញ្ជីនៅលើទីផ្សារគោល។ ការប្រមូលផ្តុំ, ការគ្រប់គ្រង និងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនឹងចីរភាពដោយសហគ្រាសធុនតូចនិងមធ្យមដែលមានលក្ខណៈជាប្រព័ន្ធ បូករួមនឹងការធ្វើសមាហរណកម្មនៃការពិចារណាអំពីចីរភាពទៅក្នុងប្រតិបត្តិការអាជីវកម្មរបស់សហគ្រាសធុនតូចនិងមធ្យម នឹងចូលរួមចំណែកពង្រឹងដល់សមិទ្ធកម្មពាក់ព័ន្ធនឹងចីរភាពជារួម, តម្លាភាព និងអនុលោមភាពរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅលើទីផ្សារគោល និងក្រុមហ៊ុនធំៗដែលមិនចុះបញ្ជីនៅលើទីផ្សារគោល។

សហគ្រាសដែលជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ ដែលអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម អាចជ្រើសរើសអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានអំពីចីរភាព។ **ន.គ.ស**. អាចរៀបចំ និងស្នើដាក់ឱ្យអនុវត្តនូវស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពសម្រាប់សហគ្រាសធុនតូចនិងមធ្យម បន្ទាប់ពីផែនទីបង្ហាញផ្លូវនេះត្រូវបានអនុម័ត។

## ជំពូកទី៥៖ ទីកន្លែង និងពេលវេលានៃការលាតត្រដាង

សហគ្រាសនឹងត្រូវបានតម្រូវឱ្យលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅរបស់ខ្លួន ដរាបណាការលាតត្រដាងព័ត៌មាន អាចរកបាននៅក្នុងផ្នែក "របាយការណ៍ចីរភាព", អាចកំណត់អត្តសញ្ញាណបានយ៉ាងច្បាស់ និងមិនត្រូវបានបិទបាំងដោយការលាតត្រដាងព័ត៌មានផ្សេងទៀត។

សម្រាប់សហគ្រាសទទួលខុសត្រូវជាសាធារណៈ, ការលាតត្រដាង ត្រូវផ្សព្វផ្សាយជាសាធារណៈ ហើយភាគីពាក់ព័ន្ធអាចទាញយកព័ត៌មានទាំងនោះយ៉ាងងាយស្រួល តាមរយៈការបោះផ្សាយនៅលើគេហទំព័ររបស់សហគ្រាស នៅក្នុងការិយបរិច្ឆេទដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដោយអាស្រ័យលើការអនុគ្រោះអន្តរកាលបន្ថែម។

## ជំពូកទី៦៖ ការអនុគ្រោះ

ដើម្បីគាំទ្រដល់យន្តការអនុវត្ត "ជាដំណាក់កាល និងសមាមាត្រ" នៃលក្ខខណ្ឌចាំបាច់ និងការអនុវត្តរបស់ក្រុមហ៊ុនដែលមានសមត្ថភាព ឬ បទពិសោធន៍នៅមានកម្រិត, សហគ្រាសរាយការណ៍អាចទាញយកអត្ថប្រយោជន៍ពីការអនុគ្រោះអន្តរកាលក្នុងដំណាក់កាលទី២ ដូចបានពិពណ៌នាក្នុងតារាងទី២៖ ការអនុគ្រោះអន្តរកាល។ តារាងទី១៖ យន្តការសមាមាត្រ រួមមានការអនុគ្រោះអចិន្ត្រៃយ៍ (សំដៅដល់ "យន្តការសមាមាត្រ" ក្នុងមគ្គុទេសក៍សម្រាប់យុត្តាធិការរបស់ ISSB) និងតារាងទី២ រួមមាន ការអនុគ្រោះអន្តរកាលបន្ថែម ដូចមានពិពណ៌នាសង្ខេបខាងក្រោម៖

- **ការអនុគ្រោះអចិន្ត្រៃយ៍៖** ផ្តួចផ្តើមគោលគំនិត "ព័ត៌មានសមហេតុផល និងអាចគាំទ្របាន ដែលអាចរកបាន នាកាលបរិច្ឆេទរាយការណ៍ ដោយមិនមានការចំណាយច្រើនលើសលប់" ដើម្បីជួយដល់សហគ្រាសក្នុងការលាតត្រដាងព័ត៌មានដែលបានតម្រូវដោយស្តង់ដាក្នុងផ្នែកដែលមានកម្រិតវាស់វែង ឬ ភាពមិនប្រាកដប្រជានៃលទ្ធផលខ្ពស់។ ការអនុគ្រោះនេះ ក៏រួមបញ្ចូលគោលគំនិត "ជំនាញ, សមត្ថភាព និងធនធានដែលមាន សម្រាប់សហគ្រាស" ដើម្បីដោះស្រាយយន្តការសមាមាត្រ និងដើម្បីធានាថា សហគ្រាសអាចអនុវត្តលក្ខខណ្ឌចាំបាច់ក្នុងមធ្យោបាយដែលសមាមាត្រទៅនឹងកាលៈទេសៈរបស់ខ្លួន ខណៈពេលដែលសហគ្រាសនៅតែអាចផ្តល់ព័ត៌មានដែលមានសារៈសំខាន់សម្រាប់វិនិយោគិន។ ការអនុគ្រោះពីស្តង់ដារបស់ ISSB ត្រូវបានអនុវត្តនៅកម្ពុជា ដោយពុំមានការកែសម្រួល។
- **ការអនុគ្រោះអន្តរកាលបន្ថែម៖** អនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានការអនុគ្រោះអន្តរកាលបន្ថែម ចំពោះលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងមួយចំនួនក្នុងស្តង់ដា IFRS S1 និង IFRS S2 សម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំ ២ (ពីរ) ឆ្នាំដំបូង សម្រាប់ការអនុគ្រោះអន្តរកាលទី១, ២, ៣, ៤ ដូចបានកំណត់នៅក្នុងតារាងទី២៖ ការអនុគ្រោះអន្តរកាល ខាងលើ។ ដោយឡែក ចំពោះការបំភាយឧស្ម័នផ្ទះកញ្ចក់ វិសាលភាពទី៣ ត្រូវបានពន្យារពេលអនុវត្ត ៣ (បី) ឆ្នាំបន្ថែម។

សហគ្រាសអាចអះអាងអនុលោមភាពតាមស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព ប្រសិនបើលក្ខខណ្ឌចាំបាច់ទាំងអស់ត្រូវបានបំពេញ ទោះបីជាលក្ខខណ្ឌចាំបាច់ទាំងអស់នោះស្ថិតក្នុងការអនុគ្រោះអន្តរកាល ស្របតាមផែនទីបង្ហាញផ្លូវនេះក៏ដោយ។

## ការហាមឃាត់ការបំពានលើការអនុគ្រោះ

ការផ្តួចផ្តើមនូវយន្តការសមាមាត្រនៅក្នុងស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព IFRS S1 និង IFRS S2 មានគោលបំណងជួយសម្រួលដល់សហគ្រាស ជាពិសេស នៅពេលស្តង់ដាត្រូវបានអនុវត្តជាលើកដំបូង។ ការណែនាំអំពីលក្ខខណ្ឌចាំបាច់សំខាន់ៗ (រួមបញ្ចូលទាំងគំរូឧទាហរណ៍) ត្រូវបានផ្តល់ជូននៅក្នុងស្តង់ដា ដើម្បីជាជំនួយដល់ការអនុវត្ត។ យន្តការទាំងនេះ អាចមានសារៈសំខាន់សម្រាប់សហគ្រាសដែលមានលទ្ធភាពតិចតួចក្នុងការអនុវត្តស្របតាមលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងរបស់ស្តង់ដា។

ដើម្បីធានាបានថា សហគ្រាសមិនបំពានលើការអនុគ្រោះអន្តរកាលដើម្បីគេចវេះពីកាតព្វកិច្ចពេញលេញ និងតម្លាភាពនៃការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងអំពីចីរភាព, សហគ្រាសរាយការណ៍ត្រូវបានហាមឃាត់មិនឱ្យជាប់ពាក់ព័ន្ធនឹងការអនុវត្តណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ស្មារតី និងគោលបំណងនៃយន្តការសមាមាត្រ ដូចមានចែងនៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ យន្តការសមាមាត្រ មានគោលបំណងអនុញ្ញាតឱ្យសហគ្រាសធ្វើការរាយការណ៍ព័ត៌មានទាក់ទងនឹងចីរភាព ក្នុងមធ្យោបាយមួយសមស្របនឹងទំហំ, ភាពស្មុគស្មាញ និងចរិតលក្ខណៈនៃសកម្មភាពរបស់ខ្លួន ខណៈដែលនៅអាចរក្សាបាននូវគុណភាពនិងភាពពេញលេញនៃព័ត៌មានដែលបានរាយការណ៍។ សហគ្រាសត្រូវបានរំពឹងថានឹងអនុវត្តយន្តការសមាមាត្រ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យស្របច្បាប់ ដូចជាទំហំ, វិស័យ និងបន្ទុកជាក់ស្តែងនៃការរាយការណ៍ ដោយធានាថា ពុំមានព័ត៌មានជាសារវន្តណាមួយត្រូវបានលុបចេញ ឬ ដាក់បង្ហាញខុស។

សម្រាប់គោលបំណងនៃឃ្លានេះ "ការបំពាន" ត្រូវបានកំណត់និយមន័យថាជាសកម្មភាព ឬភាពអសកម្មណាមួយរបស់សហគ្រាសរាយការណ៍ ដែលផ្ទុយទៅនឹងគោលបំណងនៃយន្តការសមាមាត្រ រួមបញ្ចូល ប៉ុន្តែមិនកម្រិតចំពោះការអនុវត្តខុសដោយចេតនា, ការក្លែងបន្លំព័ត៌មាន ឬ ការគេចវេះពីលក្ខខណ្ឌចាំបាច់នៃការរាយការណ៍។

## ជំពូកទី៧៖ ការពង្រឹងអនុលោមភាព និងការតាមដាន

ការលាតត្រដាងព័ត៌មានចីរភាពដែលកម្ពុជាបានអនុម័ត នឹងត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។ ការពង្រឹងការអនុវត្ត នឹងរួមបញ្ចូលនូវការផាកពិន័យសមស្របសម្រាប់សហគ្រាសដែលមិនបានអនុលោមតាមលក្ខខណ្ឌចាំបាច់ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ សហគ្រាសដែលស្ម័គ្រចិត្តអនុវត្តលក្ខខណ្ឌចាំបាច់ ឬផ្នែកណាមួយនៃលក្ខខណ្ឌចាំបាច់ មុនកាលបរិច្ឆេទកំណត់ សម្រាប់ប្រភេទនៃសហគ្រាសនោះ នឹងមិនត្រូវទទួលរងសកម្មភាពពង្រឹងការអនុវត្តនេះទេ លុះត្រាតែព័ត៌មានដែលបានដាក់បង្ហាញនាំឱ្យមានការយល់ច្រឡំ។

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ នឹងតាមដានអនុលោមភាពរបស់សហគ្រាសដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន ជាមួយលក្ខខណ្ឌចាំបាច់នៃការរាយការណ៍ក្នុងរយៈពេលផុតកំណត់ជាក់លាក់។ ការធ្វើតេស្តសាកល្បងដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទៅលើសហគ្រាសរាយការណ៍ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន ត្រូវបានអនុញ្ញាត និងលើកទឹកចិត្ត ដើម្បីធានាបាននូវយន្តការសមាមាត្រ, ភាពអាចអនុវត្តបាន និងភាពជោគជ័យនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ។

## ជំពូកទី៨៖ ការកសាងសមត្ថភាព និងការគាំទ្រ

**ន.គ.ស.** នឹងផ្តល់កម្មវិធីបណ្តុះបណ្តាល និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការផ្តល់ជូនគោលការណ៍ណែនាំ និងឯកសារគាំទ្រផ្សេងៗ ដើម្បីជួយសម្រួលដល់សហគ្រាសក្នុងការស្វែងយល់ និងអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព។

## ជំពូកទី៥៖ យន្តការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវ

**ការរៀបចំផែនការសកម្មភាព៖** ទម្រង់ផែនការសកម្មភាព នឹងត្រូវបានកំណត់ដោយគណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព។ ក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធនានា អាចរៀបចំផែនការសកម្មភាពដើម្បីគាំទ្រការអនុវត្តផែនទីបង្ហាញផ្លូវនេះពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកទៅលើទម្រង់ផែនការសកម្មភាពដែលបានកំណត់ដោយគណៈកម្មការ រួចផ្ញើជូន និយ័តករគណនេយ្យនិងសវនកម្ម ដើម្បីបូកសរុប និងជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃប្រចាំឆមាស និងប្រចាំឆ្នាំ។

**យន្តការដោះស្រាយបញ្ហាប្រឈម៖** គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព មានភារកិច្ចត្រួតពិនិត្យ និងសម្រេចដាក់ចេញវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើងក្នុងអំឡុងពេលនៃការអនុវត្តផែនទីបង្ហាញផ្លូវ។ ក្នុងករណីមានការផ្លាស់ប្តូរណាមួយ, គណៈកម្មការ ត្រូវស្នើសុំការសម្រេចពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**។

**យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖** និយ័តករគណនេយ្យនិងសវនកម្ម ទទួលបន្ទុកសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធនានា ក្នុងការអនុវត្ត, ការតាមដាន, ការត្រួតពិនិត្យ និងការវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ។ ដើម្បីធានាឱ្យការអនុវត្តផែនទីបង្ហាញផ្លូវទទួលបានជោគជ័យតាមផែនការដែលបានគ្រោងទុក, ក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធនានា អាចរៀបចំ និងផ្ញើរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំជូន និយ័តករគណនេយ្យនិងសវនកម្ម ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការតាមដាន និងត្រួតពិនិត្យការអនុវត្ត និងរាយការណ៍វឌ្ឍនភាពការងារជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**។

## ជំពូកទី១០៖ វិសោធនកម្ម

គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព អាចចេញផ្សាយវិសោធនកម្មលើផែនទីបង្ហាញផ្លូវនេះ តាមការចាំបាច់ ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា។

# សមាសភាព

# គណៈកម្មការបច្ចេកទេស

# សម្រាប់ការរាយការណ៍

# ព័ត៌មានចីរភាព

**ផែនទីបង្ហាញផ្លូវ សម្រាប់ការអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាពនៅកម្ពុជា** ត្រូវបានរៀបចំឡើងដោយគណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព ហៅកាត់ថា «**គ.រ.ច.**» នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលបង្កើតឡើងដោយសេចក្តី-សម្រេចលេខ ០១០ អ.ស.ហ.សសរ ចុះថ្ងៃទី៥ ខែសីហា គ.ស.២០២៥។

គណៈកម្មការបច្ចេកទេសនេះ ដឹកនាំផ្ទាល់ដោយ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព ដែលមានសមាសភាពដូចខាងក្រោម៖

- លោកស្រី **នាន បូនី** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម
- ឯកឧត្តម **ហឿន សំនៀង** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- លោក **នូ បូណាភក្តី** តំណាងក្រសួងផែនការ
- ឯកឧត្តម **ភួប រ៉ៃលី** តំណាងក្រសួងបរិស្ថាន
- លោកស្រី **ម៉ក់ ស្មឹ** តំណាងធនាគារជាតិនៃកម្ពុជា
- កញ្ញា **ជា យ៉ាអ៊ីម** តំណាងនិយ័តករមូលបត្រកម្ពុជា
- លោកស្រី **តាន់ លីនណា** តំណាងនិយ័តករធានារ៉ាប់រងកម្ពុជា
- លោក **ឈួន សុធី** តំណាងវិទ្យាស្ថានជាតិស្ថិតិ
- លោកស្រី **ពេជ្រ ម៉ានីឡា** ប្រធាននាយកដ្ឋានបច្ចេកទេសនៃនិយ័តករគណនេយ្យនិងសវនកម្ម
- លោក **ឃុន ដារិទ្ធ** តំណាងក្រុមហ៊ុន ខេ ប្រឹហ្វេសិនណល អឹខោនថិន
- លោក **នៅ រ៉េមី** តំណាងក្រុមហ៊ុន ប្រាយតែជ័រហោវខូភើស៍ (ខេមបូឌា)
- កញ្ញា **សុខ ស្រីរដ្ឋា** តំណាងក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត
- លោក **អ៊ុំខ គឹមសុភ័ត្រា** តំណាងក្រុមហ៊ុន ឌី ឡ័យធ៍ (ខេមបូឌា) ខូ អិលធីឌី
- លោក **យឹម ឡុងឌី** តំណាងក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា

**គ.រ.ច.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការរដ្ឋបាល និងបច្ចេកទេស ដែលត្រូវបានតែងតាំងដោយសេចក្តីសម្រេចលេខ ០០១/២៦ ន.គ.ស. / គ.រ.ច. ចុះថ្ងៃទី ១៨ ខែឧសភា គ.ស. ២០២៦ របស់និយ័តករគណនេយ្យនិងសវនកម្ម ដែលមានសមាសភាពដូចខាងក្រោម៖

- លោក **ហេង សំណាង** អនុប្រធាននាយកដ្ឋាន នៃ **ន.គ.ស.**
- លោក **ប៉ុក ជ័យរិទ្ធី** អនុប្រធានការិយាល័យ នៃ **ន.គ.ស.**
- លោកស្រី **សុន មួយគាង** មន្ត្រីបច្ចេកទេស នៃ **ន.គ.ស.**

- លោក **ឡៀង ពិណ្ណាដា** អនុប្រធានការិយាល័យ នៃ **ន.គ.ស.**
- កញ្ញា **ខួន ច័ន្ទរដ្ឋា** អនុប្រធានការិយាល័យ នៃ **ន.គ.ស.**
- លោកស្រី **ជីប រចនា** មន្ត្រីបច្ចេកទេស នៃ **ន.គ.ស.**
- កញ្ញា **ឡាំ ដាណេ** មន្ត្រីបច្ចេកទេស នៃ **ន.គ.ស.**
- លោក **គីម សុវណ្ណា** មន្ត្រីបច្ចេកទេស នៃ **ន.គ.ស.**
- លោក **គង់ ពិចិត្រឧត្តម** មន្ត្រីបច្ចេកទេស នៃ **ន.គ.ស.**
- កញ្ញា **សែម មុនីនាថ** មន្ត្រីបច្ចេកទេស នៃ **ន.គ.ស.**




t.me/acarcambodia

www.facebook.com/acarcambodia

info@acar.gov.kh

+(៨៥៥) ២៣ ៨៨២ ១១១

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទំនាក់ទំនងតាមរយៈ:

បណ្ដាញសង្គមផ្លូវការ

KINGDOM OF CAMBODIA

NATION RELIGION KING

# Roadmap for the Adoption of IFRS Sustainability Disclosure Standards in Cambodia



Prepared by

Sustainability Reporting Technical Committee

2026

**Kingdom of Cambodia**
**Nation Religion King**

# Roadmap for the Adoption of IFRS Sustainability Disclosure Standards in Cambodia

**Prepared by**
**Sustainability Reporting Technical Committee**
**2026**

(Unofficial Translation)

# Preface

Cambodia, under the wise leadership of **Samdech Akka Moha Sena Padei Techo Hun Sen**, the former Prime Minister and current President of the Senate, has successfully implemented the Triangular Strategy and the Four-Phase Rectangular Strategy through the Win-Win Policy with major achievements across all political, social, and economic sectors, achieving a commendable and historic transformation of Cambodia.

